ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ ០៦៦ ប្រ.ក

# ប្រកាស
# ស្តីពី
# ការធ្វើចំណាត់ថ្នាក់និងការផ្តល់ទិដ្ឋាការភាពយន្តនិងវីដេអូ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក. ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងក្រុមពិនិត្យសិល្បៈភាពយន្ត និង វីដេអូ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

ប្រការ១.-

ប្រកាសនេះមានគោលបំណងពង្រឹងការផលិតនិងការចែកចាយផលិតផលស្នាដៃភាពយន្តនិងវីដេអូខ្មែរ និង បរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចៀសផលប៉ះពាល់អវិជ្ជមានលើផ្នែកស្មារតីរបស់អនីតិជន ជាពិសេសកុមារ។/.

**ប្រការ២.-**

ត្រូវបានកំណត់បែងចែកស្នាដៃភាពយន្តនិងវីដេអូជា៣(បី)ថ្នាក់ដើម្បីផ្តល់ទិដ្ឋាការភាពយន្តដូចខាងក្រោម៖

ក.សញ្ញាសម្គាល់ **ឧ.ឧ.** ឬ **G** ជាប្រភេទស្នាដៃភាពយន្តនិងវីដេអូដែលអនុញ្ញាតចំពោះទស្សនិកជនទូទៅ

ខ.សញ្ញាសម្គាល់ **ហ.ឧ.១៥** ឬ **NC15** ជាប្រភេទស្នាដៃភាពយន្តនិងវីដេអូដែលអនុញ្ញាតចំពោះទស្សនិកជនដែលមានអាយុចាប់ពី១៥(ដប់ប្រាំ)ឆ្នាំឡើងទៅ

គ.សញ្ញាសម្គាល់ **ហ.ឧ.១៨** ឬ **R18** ជាប្រភេទស្នាដៃភាពយន្តនិងវីដេអូដែលអនុញ្ញាតចំពោះទស្សនិកជនដែលមានអាយុចាប់ពី១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ

**ប្រការ៣.-**

ស្នាដៃភាពយន្តនិងវីដេអូដែលបានទទួលចំណាត់ថ្នាក់ដូចមានចែងក្នុងចំណុច«ខ» នៃប្រការ២ ករណីយកទៅផ្សព្វផ្សាយតាមប្រព័ន្ធទូរទស្សន៍ ឬ ទូរទស្សន៍ខ្សែកាប ឬ ធ្វើអាជីវកម្មបញ្ចាំងចល័ត ឬ ផ្សព្វផ្សាយតាមទូរផ្សាយជាសាធារណៈដទៃទៀតអាចចាក់បញ្ចាំងបាននៅចន្លោះម៉ោង១០:០០យប់ទៅម៉ោង៦:០០ព្រឹក។

ក្នុងករណីផ្សព្វផ្សាយជាលក្ខណៈអាជីវកម្មជួល ឬ លក់ត្រូវអនុវត្តឱ្យបានសមស្របតាមការកំណត់គឺជួល លក់ឱ្យតែអតិថិជនមានអាយុចាប់ពី១៥(ដប់ប្រាំ)ឆ្នាំឡើងទៅ។

**ប្រការ៤.-**

ស្នាដៃភាពយន្តនិងវីដេអូដែលបានទទួលចំណាត់ថ្នាក់ដូចមានចែងក្នុងចំណុច«គ» នៃប្រការ២ អនុញ្ញាតឱ្យធ្វើអាជីវកម្មបញ្ចាំងតែក្នុងរោងភាពយន្តប៉ុណ្ណោះ។

**ប្រការ៥.-**

ស្នាដៃភាពយន្តនិងវីដេអូ សម្រាប់ធ្វើការចាក់បញ្ចាំងផ្សព្វផ្សាយជាសាធារណៈតាមគ្រប់មធ្យោបាយផ្សព្វផ្សាយ ឬ ដាក់តាំងលក់ ជួល ចាំបាច់ត្រូវដាក់បង្ហាញសញ្ញាសម្គាល់ដូចមានក្នុងចំណុច ក ខ គ នៃប្រការ២ នៅលើផ្ទៃរឿង បណ្ណឃោសនា និងប្រអប់វេចខ្ចប់សម្ភារៈផ្ទុកស្នាដៃភាពយន្តនិងវីដេអូនោះ។

**ប្រការ៦.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសិល្បភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត គណៈកម្មការពិនិត្យខ្លឹមសារ រូបភាព និងចំណាត់ថ្នាក់ភាពយន្ត ព្រមទាំងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ភឿង-សកុណា

**កន្លែងទទួល** :
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ
- -សាលារាជធានី ខេត្ត
- -ដូចប្រការ៧ "ដើម្បីអនុវត្តន៍"
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ